ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២០៥ សហវ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការតែងតាំងភ្នាក់ងារបើកផ្តល់សំរាប់បើកប្រាក់បៀវត្សរ៍ និងប្រាក់អត្ថាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ ជូនមន្ត្រីរាជការនៅក្រសួងផែនការ

---

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រដ្ឋមន្ត្រី ក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាលេខ ន.ស.រ.ក.ត ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២.នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤.
- បានឃើញព្រះរាជក្រមលេខ ០១នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១៦នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស.រកម.១២៩៩.១៥ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៩.
- បានឃើញព្រះរាជក្រមលេខ នស.រកម ១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២.
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ.
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ.
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅនៃគណនេយ្យ សាធារណៈ.
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន.

## សំរេច

<u>ប្រការ១</u> : - ប្រាក់បៀវត្សរ៍ និងប្រាក់អត្ថភាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌របស់មន្ត្រីរាជការនៃក្រសួងផែនការនឹងត្រូវបើកផ្តល់តាមរយៈ " ភ្នាក់ងារបើកផ្តល់ "

<u>ប្រការ២</u> : - លោក រុន នារ៉ុន ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់នៅក្រសួងផែនការ.

- លោក គន់ សុផារ៉ា ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់ជំនួសនៅក្រសួងផែនការ.

<u>ប្រការ៣</u> : - លោក រុន នារ៉ុន និង លោក គន់ សុផារ៉ា ត្រូវបានអនុញ្ញាតិអោយបើកគណនីប្រាក់បញ្ញើនៅរតនាគារជាតិ ដើម្បីទទួលមូលនិធិសំរាប់យកទៅបើកប្រាក់បៀវត្សរ៍និងប្រាក់អត្ថភាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ជូនមន្ត្រីរាជការ.

<u>ប្រការ៤</u> : - របៀបបទនៃការអនុវត្តន៍ បើកផ្តល់ប្រាក់បៀវត្សរ៍និងប្រាក់អត្ថភាគមន៍ក្នុងវិស័យ សង្គមកិច្ចនិងវប្បធម៌ នឹងត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ.

<u>ប្រការ៥</u> : - ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និង មូលនិធិដែលបានទទួល ដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ .

<u>ប្រការ៦</u> : - សេចក្តីសំរេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍.

<u>ប្រការ៧</u> : - អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងផែនការព្រមទាំងលោក រុន នារ៉ុន និង លោក គន់ សុផារ៉ា មានភារកិច្ចទទួលបន្ទុក អនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០០២

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**គាត ឈន់**

រដ្ឋមន្ត្រីក្រសួងផែនការ

**ឆាយ ថន**

<u>**កន្លែងទទួល**</u>

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៧

" ដើម្បីអនុវត្ត "

- ឯកសារ-កាលប្បវត្តិ